ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីអំពាវនាវ

អនុលោមតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ស្តីពីសម្ព័ន្ធមេត្រីភាពរវាងកងទ័ព កងនគរបាលជាតិ ជាមួយស្ថាប័ន អង្គភាពស៊ីវិល ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំ និងមន្រ្តីរាជការក្រោមឱវាទក្រសួង ក៏ដូចជាភ្នាក់ងារជ្រើសរើសឯកជន និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឯកជនទាំងអស់ មេត្តាជ្រាបថា ដើម្បីរឹតចំណងសម្ព័ន្ធមេត្រីភាពជាមួយកងពលតូចអន្តរាគមន៍លេខ០៧ ដែលកំពុងឈរជើងការពារតាមតំបន់ព្រំដែនខេត្តព្រះវិហារ ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឯកឧត្តមបណ្ឌិត **អ៊ិត សំហេង** នឹងដឹកនាំប្រតិភូ ចុះសួរសុខទុក្ខ និងរៀបចំពិធីសំណេះសំណាលជាមួយបងប្អូន និងគ្រួសារយុទ្ធជន នៅថ្ងៃអាទិត្យ ទី១០ ខែមេសា ឆ្នាំ២០១៦ វេលាម៉ោង ០៨.៣០នាទីព្រឹក នៅទីបញ្ជាការកងពល ស្ថិតនៅក្នុង ភូមិសែនជ័យ ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។

ក្នុងស្មារតីនេះ ក្រសួងសូមអំពាវនាវដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ មេត្តាជួយឧបត្ថម្ភនូវ ថវិកា សម្ភារ និងគ្រឿងឧបភោគបរិភោគនានាតាមសទ្ធាជ្រះថ្លា ដើម្បីលើកទឹកចិត្ត និងគាំទ្រដល់ស្មារតីក្លាហានស្នេហាជាតិរបស់បងប្អូនកងទ័ពយើង។

ក្រសួងសង្ឃឹមជឿជាក់ថា ឯកឧត្តម លោកជំទាវ លោក លោកស្រី នឹងចូលរួមគាំទ្រសកម្មភាពនេះ ដើម្បីរួមចំណែកជាមួយកងពលខាងលើឱ្យបានច្រើនកុះករ។

<u>បញ្ជាក់</u>៖ - រសៀលថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៦ ចេញដំណើរដោយមធ្យោបាយផ្ទាល់ខ្លួន

- ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៦ វេលាម៉ោង ០៧.៣០នាទីព្រឹក ជួបជុំគ្នានៅទីប្រជុំជនឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែ មីនា ឆ្នាំ២០១៦

ត.ប រដ្ឋមន្ត្រី
នាយកខុទ្ទកាល័យ

ហេង_សួរ

សូមទំនាក់ទំនងខុទ្ទកាល័យ
-ល. ងុយ រិទ្ធ ០១២ ៨៥៥ ០៧៥
-ល. ទៀវ ម៉ាក់តែល ០១២ ៨២៣ ៣៧៥
-ល. អ៊ូច ពិសី ០៩៥ ៥០០ ០៨៧



Scanned by CamScanner